# ការណែនាំសម្រាប់ឧស្សាហកម្ម៖
## គាំទ្រអ្នកដើម្បីអនុលោមតាម
## កាតព្វកិច្ចចំពោះបរិស្ថានទូទៅ

EPA VICTORIA | Environment Protection Authority Victoria | VICTORIA State Government

ការបោះពុម្ពផ្សាយលេខ ១៧៨១ ខែមេសា ឆ្នាំ២០១៩ Translated publication: 1781 សន្លឹកព័ត៌មាន

ក្របខ័ណ្ឌច្បាប់ថ្មីនឹងចាប់អនុវត្តនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។ ក្របខ័ណ្ឌនេះនឹងធ្វើឱ្យប្រាកដថាមនុស្សគ្រប់គ្នាទទួលខុសត្រូវចំពោះហានិភ័យដែលបង្កឡើងដល់បរិស្ថាន។ កាតព្វកិច្ចចំពោះបរិស្ថានទូទៅ (GED) អនុវត្តចំពោះពលរដ្ឋវិចថូរៀទាំងអស់។ នៅក្រោម GED យើងត្រូវតែយល់ដឹង និងកាត់បន្ថយហានិភ័យរបស់យើងដល់សុខភាពមនុស្ស និងបរិស្ថានតាមរយៈការបំពុល និងកាកសំណល់។ GED គាំទ្រគោលដៅនៃ *ច្បាប់ការពារបរិស្ថាន ឆ្នាំ២០១៧* (ច្បាប់)។

យើងនឹងធ្វើការជាមួយអាជីវកម្ម ដើម្បីជួយពួកគេឱ្យបានយល់ដឹងពីរបៀបបំពេញកាតព្វកិច្ចរបស់ពួកគេ។ យើងនឹងផ្តល់ការណែនាំ ដំបូន្មាន និងការគាំទ្រផ្សេងៗទៀត។

ដើម្បីអនុលោមតាម GED អាជីវកម្មចាំបាច់ត្រូវ៖

- អនុវត្តជំហានជាក់ស្តែង
- ប្រើការអនុវត្តការងារបរិស្ថានល្អ។

## ការបំពេញកិច្ចការនៅក្រោម GED

អាជីវកម្មភាគច្រើននឹងមិនធ្វើអ្វីឱ្យខុសប្លែកគ្នាទេនៅក្រោម GED។ អាជីវកម្មជាច្រើនបំពេញតាមការអនុវត្តន៍ល្អៗ ដែលជួយពួកគេឱ្យអនុវត្តតាម GED។ ការអនុវត្តទាំង នេះរួមមាន៖

- ការបំពេញតាមការទទួលខុសត្រូវលើសុខភាព និងសុវត្ថិភាពការងារ
- ការបំពេញតាមស្តង់ដារឧស្សាហកម្ម
- ការប្រើប្រាស់ការអនុវត្តគ្រប់គ្រងផ្នែកឧស្សាហកម្មល្អបំផុត
- ការអនុវត្តតាមច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងបរិស្ថាន។

GED គ្រាន់តែធ្វើឱ្យវាច្បាស់ប្រាកដថា អ្នកត្រូវគ្រប់គ្រងអាជីវកម្មរបស់អ្នក ដើម្បីកាត់បន្ថយហានិភ័យណាមួយចំពោះបរិស្ថាន។

ប្រសិនបើអ្នកមិនច្បាស់អំពីអ្វីដែលអ្នកគួរធ្វើដើម្បីការពារបរិស្ថាន នោះ GED អាចជួយបាន។ GED ផ្តល់ឱ្យអ្នក និងយើងនូវក្របខ័ណ្ឌច្បាស់លាស់មួយដើម្បីអនុវត្តតាម ឱ្យបានយល់ដឹងពីហានិភ័យ ហើយចាត់វិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។

ចំពោះអាជីវកម្មទាំងឡាយណាដែលមិនធ្វើអ្វីត្រឹមត្រូវ ច្បាប់នេះធ្វើពួកគេបានយល់ច្បាស់ពីកាតព្វកិច្ចរបស់ពួកគេ។ វាក៏ផ្តល់ឱ្យយើងដែរនូវឧបករណ៍ទាំងឡាយដើម្បីស្វែងរក និងធ្វើឱ្យពួកគេអនុលោមតាម។ កម្រិតនេះ គឺជាទីចាប់ផ្តើមសម្រាប់មនុស្សគ្រប់គ្នា។

**និយមន័យ៖** "បុគ្គលណាម្នាក់ដែលចូលរួមក្នុងសកម្មភាពមួយ ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស ឬបរិស្ថានពីការបំពុល ឬកាកសំណល់ ត្រូវតែកាត់បន្ថយហានិភ័យទាំងនោះឱ្យសមហេតុផល ដែលអាចធ្វើទៅបាន"។

**សមហេតុផលដែលអាចធ្វើទៅបាន** អាចមានន័យថា ការដាក់នៅក្រោមការគ្រប់គ្រង ដើម្បីត្រួតពិនិត្យហានិភ័យ ដែលស្មើនឹងហានិភ័យ។

វាទាក់ទងទៅនឹងឱកាសនៃការប៉ះពាល់ និងផលប៉ះពាល់ដែលអាចកើតមានចំពោះបរិស្ថាន។ វាក៏ទាក់ទងនឹង៖

- តើមានការគ្រប់គ្រងអ្វីខ្លះ
- តើវាត្រូវចំណាយអស់ប៉ុន្មាន
- តើអាជីវកម្ម ជាទូទៅដឹងអ្វីខ្លះអំពីហានិភ័យ នេះត្រូវបានគេហៅថា "ស្ថានភាពនៃចំណេះដឹង"
- តើពួកគេមានជម្រើសអ្វីខ្លះដើម្បីគ្រប់គ្រងវា។

### ព័ត៌មានបន្ថែម

*ទាក់ទងមកយើង៖* **www.epa.vic.gov.au**

***1300 372 842*** *(1300 EPA VIC)*

**ការណែនាំពីឧស្សាហកម្ម៖**
www.epa.vic.gov.au/business-and-industry/guidelines

**ការផ្លាស់ប្តូរចូលទៅកាន់ច្បាប់ថ្មី៖**
www.epa.vic.gov.au/newlaws

**ការយល់ដឹងអំពីច្បាប់ថ្មី៖**
engagement@epa.vic.gov.au

Authorised and published by
Environment Protection Authority Victoria
200 Victoria Street, Carlton VIC 3053
**W** epa.vic.gov.au | **T** 1300 372 842 (1300 EPA VIC)

Interpreter

If you need interpreter assistance or want this document translated please call **131 450** and advise your preferred language.

If you are deaf, or have a hearing or speech impairment, contact us through the National Relay Service. For more information, visit: **www.relayservice.gov.au**

# គាំទ្រអ្នកដើម្បីអនុលោមតាមកាតព្វកិច្ចចំពោះបរិស្ថានទូទៅ

## ការយល់ដឹងពីស្ថានភាពនៃចំណេះដឹង

ស្ថានភាពនៃចំណេះដឹង ពិពណ៌នាអំពីអ្វីដែលអាជីវកម្មដឹង ឬគួរដឹងអំពីគ្រោះថ្នាក់ ឬហានិភ័យនៃគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស និងបរិស្ថាន។ វាក៏ពិពណ៌នាដែរអំពីអ្វីដែលពួកគេដឹង អំពីការគ្រប់គ្រងដែលអាចកម្ចាត់ ឬកាត់បន្ថយហានិភ័យទាំងនោះ។

នៅក្រោម GED អ្នកចាំបាច់ត្រូវដឹងអំពីហានិភ័យដែលសកម្មភាពរបស់អ្នកអាចមាន និងរបៀបកាត់បន្ថយវា។

ដើម្បីទទួលបានចំណេះដឹងនេះ អ្នកត្រូវប្រើប្រភពដែលអាចទុកចិត្តបាន និងគួរឱ្យទុកចិត្តបាន។ អ្នកអាចទទួលបានព័ត៌មាននេះតាមរយៈ៖

- អាជីវកម្ម និងឧស្សាហកម្មរបស់អ្នក
- និយតករ និងភ្នាក់ងាររដ្ឋាភិបាល
- អង្គការឯករាជ្យ។

**ចំណេះដឹងអាជីវកម្ម និងឧស្សាហកម្ម** អាចរួមមាន៖

- ឯកសារ និងនីតិវិធីអាជីវកម្ម ដើម្បីអនុវត្តសកម្មភាពដោយសុវត្ថិភាព
- សៀវភៅណែនាំ និងព័ត៌មានពីអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការ
- សន្លឹកទិន្នន័យ និងស្លាកសញ្ញាសុវត្ថិភាព
- ការណែនាំរបស់អ្នកផលិត អំពីការប្រើប្រាស់ផលិតផលដោយសុវត្ថិភាព
- ការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ឧបករណ៍
- ការរៀបចំកិច្ចសន្យារវាងអស់អ្នកដែលចូលរួមក្នុងសកម្មភាព
- ឯកសារ សៀវភៅណែនាំ និងការណែនាំពីសមាគមឧស្សាហកម្ម និងស្ថាប័នកំពូល។

**ចំណេះដឹងរបស់និយតករ និងភ្នាក់ងាររដ្ឋាភិបាល** ពី EPA និងអាជ្ញាធររដ្ឋាភិបាលដទៃទៀត (រួមទាំងនិវន្តភាពវិចថូរៀ និង WorkSafe) អាចរួមមាន៖

- សេចក្តីណែនាំ និងកំណត់ត្រាបច្ចេកទេស
- ការសម្រេចចិត្តអំពីលទ្ធផលនៃការអនុលោមតាម និងការអនុវត្ត
- ជំនួយ (រួមមានការផ្តល់ជំនួយដល់អាជីវកម្មរបស់អ្នក ជាពិសេស)។

**ចំណេះដឹងរបស់អង្គការឯករាជ្យ** អាចរួមបញ្ចូលរបាយការណ៍ពីអង្គការនានាដូចជា៖

- បទដ្ឋានអូស្ត្រាលី
- សាកលវិទ្យាល័យ
- វិស្វករបរិស្ថាន។

ស្ថានភាពនៃចំណេះដឹងនឹងផ្លាស់ប្តូរ នៅពេលដែលបច្ចេកវិទ្យាថ្មី ប្រព័ន្ធ និងដំណើរការអភិវឌ្ឍ ឬនៅពេលហានិភ័យថ្មីកើតមានឡើង។

## របៀបដែលយើងអាចរួមចំណែកដល់ស្ថានភាពនៃចំណេះដឹង

យើងនឹងធ្វើការជាមួយឧស្សាហកម្ម ដើម្បីបង្កើតការណែនាំដើម្បីជួយដល់អាជីវកម្មកំណត់ និងគ្រប់គ្រងហានិភ័យ។

នេះអាចរួមមាន៖

- ការផ្តល់ព័ត៌មានអំពីសារសំខាន់នៃបញ្ហាសុខភាព និងបរិស្ថាន
- ការគាំទ្រគំនិតផ្តួចផ្តើមដែលការណែនាំអាចមានប្រយោជន៍ក្នុងការអប់រំអាជីវកម្មអំពីបទបញ្ញត្តិច្បាប់
- ការអប់រំអាជីវកម្ម ក្រោយពីសមាជិកឧស្សាហកម្ម មិនអនុលោមតាម ឬធ្វេសប្រហែសមិនអនុលោមតាម ម្តងហើយម្តងទៀតយ៉ាងធ្ងន់ធ្ងរ ។

អ្នកក៏អាចទាក់ទងសមាគមឧស្សាហកម្មរបស់អ្នកបានដែរ។



*សម្រាប់ព័ត៌មានបន្ថែម អំពីរបៀបគ្រប់គ្រងផលប៉ះពាល់បរិស្ថានរបស់អ្នក*

epa.vic.gov.au/business-and-industry/how-to-manage-your-environmental-impact